# អំណាចព្យាបាលនៃការដឹងគុណ

**ដោយប្រធាន រ័សុល អិម ណិលសុន**
*ប្រធានសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ*

*ជាវេជ្ជបណ្ឌិត ខ្ញុំស្គាល់តម្លៃនៃការព្យាបាលល្អ ។ ដូច្នេះ មិត្តជាទីស្រឡាញ់ ខ្ញុំសូមចេញវេជ្ជបញ្ជាពីរយ៉ាង ដើម្បីជួយយើងពិសោធន៍អំណាចព្យាបាលនៃការដឹងគុណ ។*

ក្នុងអំឡុងពេល ៩៦ ឆ្នាំនៃជីវិតខ្ញុំ ខ្ញុំបានឃើញវិបត្តិសេដ្ឋកិច្ច សង្គ្រាមលោក កំណើននៃភេរវកម្ម ភាពអត់ឃ្លាន និងភាពក្រីក្រនៅទូទាំងពិភពលោក ។ ខ្ញុំក៏បានធ្វើជាសាក្សីដល់វត្តមាននៃការធ្វើដំណើរលើអវកាស អ៊ីនធឺណិត វឌ្ឍនភាពផ្នែកវេជ្ជសាស្ត្រ និងការរកឃើញរាប់មិនអស់ដែលធ្វើឲ្យខ្ញុំរីករាយ ។

ពីមុនការងារបម្រើខ្ញុំ ខ្ញុំជាវេជ្ជបណ្ឌិតផ្នែកវះកាត់សរសៃឈាមបេះដូង និង បំពង់-ក ហើយបានចំណាយពេលរាប់ម៉ោងក្នុងបន្ទប់វះកាត់ ។ ក្នុងនាមជាអ្នកវះកាត់ ខ្ញុំជាសមាជិកនៃក្រុមស្រាវជ្រាវដែលបានបង្កើតម៉ាស៊ីនបេះដូង-សួតដើម្បីប្រើនៅក្នុងការវះកាត់បេះដូងមនុស្ស ។[១] ក្រោយមក ខ្ញុំមានអភ័យឯកសិទ្ធិជួយសង្គ្រោះជីវិតអ្នកជំងឺរាប់រយនាក់ ហើយជាអកុសល ខ្ញុំក៏ធ្លាប់ឈរមើលអ្នកជំងឺផ្សេងទៀតស្លាប់ដែរ ទោះបីជាខ្ញុំខិតខំអស់ពីសមត្ថភាពក្ដី ។

ក្នុងនាមជាអ្នកវិទ្យាសាស្ត្រ និងអ្នកមានជំនឿ ជំងឺរាតត្បាតទូទាំងពិភពលោកបច្ចុប្បន្ននេះ ធ្វើឲ្យខ្ញុំមានកង្វល់ជាខ្លាំង ។ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រ ខ្ញុំកោតសរសើរចំពោះការបង្ការជាចាំបាច់ដល់ការរីករាលដាលនៃការឆ្លងនេះ ។ ខ្ញុំក៏សូមអរគុណដល់អ្នកជំនាញផ្នែកសេវាថែទាំសុខភាពដែលបានលះបង់ ហើយសោកស្ដាយចំពោះមនុស្សជាច្រើនដែលបានស្លាប់ដោយកូវីដ-១៩ ។

តែ ក្នុងនាមជាអ្នកជឿ ខ្ញុំមើលឃើញជំងឺរាតត្បាតបច្ចុប្បន្នថាជាជំងឺមួយក្នុងចំណោមជំងឺដែលញាំញីពិភពលោកយើង រួមមានការស្អប់ខ្ពើម ចលាចលក្នុងសង្គម ការរើសអើងជាតិសាសន៍ អំពើហឹង្សា ភាពមិនស្មោះត្រង់ និងការខ្វះសុជីវធម៌ ។

ពួកអ្នកវិទ្យាសាស្ត្រ និងពួកអ្នកស្រាវជ្រាវដ៏ជំនាញកំពុងព្យាយាមយ៉ាងខ្លាំងដើម្បីបង្កើត និងចែកចាយវ៉ាក់សាំងការពារវីរុសក្ស័យណា ។ ប៉ុន្តែគ្មានថ្នាំពេទ្យ ឬការវះកាត់ណាមួយ ដែលអាចជួសជុលសេចក្តីវេទនា និងជំងឺខាងវិញ្ញាណជាច្រើនដែលយើងជួបនោះឡើយ ។

តែ ក៏មានឱសថម៉្យាង—ជាឱសថមួយដែលទំនងជាធ្វើឲ្យមានការភ្ញាក់ផ្អើល ដោយសារវាផ្ទុយពីសភាវគតិពីធម្មជាតិរបស់យើង ។ ទោះជាបែបនេះក្តី ក៏ឥទ្ធិពលវាមានសុពលភាពដល់ពួកអ្នកវិទ្យាសាស្ត្រក៏ដូចជាបុរសស្ត្រីដែលមានជំនឿផងដែរ ។

ខ្ញុំសំដៅទៅលើអំណាចព្យាបាលនៃ*ការដឹងគុណ* ។

គម្ពីរទំនុកដំកើងមានពេញទៅ ដោយដំបូន្មានឲ្យបង្ហាញនូវការដឹងគុណ ។ នេះជាដំបូន្មានចំនួនបី ៖

« នេះជាការល្អហើយ គឺដែលនឹងអរព្រះគុណដល់ព្រះយេហូវ៉ា » ។[២]

« ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ » ។[៣]

« ចូលទៅចំពោះទ្រង់ ដោយអរព្រះគុណ » ។[៤]

ព្រះយេស៊ូវ គ្រីស្ទបានបង្ហាញការដឹងគុណជាញឹកញាប់ ។ ពីមុនប្រោសឡាសារឲ្យរស់ពីស្លាប់ ពីមុនធ្វើឲ្យនំប៉័ងនិងត្រីមានច្រើនដោយអព្ភូតហេតុ និងពីមុនហុចពែងទៅឲ្យពួកសិស្សរបស់ទ្រង់នៅឯអាហារចុងក្រោយ នោះព្រះអង្គសង្គ្រោះបានអធិស្ឋាន ហើយថ្លែងអំណរគុណចំពោះព្រះ ។ ពុំគួរឆ្ងល់ទេ ដែលសាវកប៉ុល ក្រោយមកប្រកាសថា « ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់ » ។[៥]

ក្នុងរយៈពេលប្រាំបួនទសវត្សរ៍កន្លះនៃជីវិតខ្ញុំ ខ្ញុំបានសន្និដ្ឋានថា *ការរាប់*ពរជ័យរបស់យើងគឺប្រសើរជាង*ការរាប់*បញ្ហារបស់យើងឆ្ងាយណាស់ ។  មិនថាស្ថានភាពរបស់យើងយ៉ាងណាទេ ការបង្ហាញការដឹងគុណចំពោះឯកសិទ្ធិរបស់យើងគឺជាឱសថខាងវិញ្ញាណជាសះស្បើយឆាប់ និងយូរអង្វែង ។

តើការដឹងគុណជួយយើងពីទុក្ខសោក ក្តីសោកសៅ ទុក្ខព្រួយ និងការឈឺចាប់ឬទេ ? អត់ទេ ប៉ុន្តែវាធ្វើឲ្យយើងបានធូរស្រាល ។ វាបើកទស្សនវិស័យយើងកាន់តែធំអំពីគោលបំណង និងអំណរនៃជីវិត ។

ជិតដប់ប្រាំមួយឆ្នាំ កន្លងទៅ ភរិយាខ្ញុំ ដាន់សិល និងខ្ញុំបានអង្គុយនៅលើសាឡុងកាន់ដៃគ្នា ខណៈដែលយើងកំពុងមើលទូរទស្សន៍ ។ រំពេចនោះ គាត់បានដួល ។

ទោះជាបានហាត់រៀនយ៉ាងល្អ ដើម្បីព្យាបាលជំងឺដែលអាចបញ្ចប់ជីវិតប្រពន្ធក្តី ក៏ខ្ញុំមិនអាចជួយជីវិតនាងបានដែរ ។

ដាន់សិល និងខ្ញុំទទួលពរមានកូនស្រី៥នាក់ និងកូនប្រុសម្នាក់ ។ ជាអកុសល ខ្ញុំបានបាត់បង់កូនស្រីពីរនាក់ដោយសារជំងឺមហារីក ។ គ្មានឪពុកម្តាយណាត្រៀមចិត្តបាត់បង់កូននោះទេ ។

ប៉ុន្តែ ទោះបីជាជួបការពិបាកទាំងនេះ និងផ្សេងៗទៀតក្តី ក៏ ខ្ញុំពិតជាមាន*អំណរគុណ*ដ៏អស់កល្បជានិច្ចចំពោះអ្វីៗជាច្រើនផងដែរ ។

ខ្ញុំអរគុណព្រះ សម្រាប់រយៈពេលជិត ៦០ ឆ្នាំ ដែល ដាន់សិល និងខ្ញុំមានជាមួយគ្នាសម្រាប់ក្តីស្រឡាញ់ពេញមួយជីវិត និងអំណរ និងអនុស្សាវរីយ៍រីករាយនានា ។ ខ្ញុំអរព្រះគុណទ្រង់ចំពោះវិនឌី ដែលខ្ញុំបានជួបក្រោយពីដាន់សិលចែកឋានទៅ ។ ឥឡូវគាត់បំពេញជីវិតខ្ញុំដោយអំណរ ។

ខ្ញុំអរគុណព្រះ សម្រាប់ពេលដែលខ្ញុំមានជាមួយកូនស្រីទាំងពីរនាក់ដែលស្លាប់ទៅនោះ ។ ដួងចិត្តរបស់ឪពុករូបនេះបានរសាយនៅពេលខ្ញុំបានឃើញឥរិយាបទនៃកូនស្រីទាំងនោះមាននៅលើទឹកមុខដ៏ថ្លៃថ្លានៃកូនៗ និងចៅៗរបស់ពួកគេ ។

យើងទាំងអស់គ្នាអាចថ្លែងអំណរគុណសម្រាប់ភាពស្រស់ស្អាតនៃផែនដី និងភាពរុងរឿងនៃ ស្ថានសួគ៌ដែលបានផ្តល់ឲ្យយើងនូវភាពដ៏ធំធេងនៃភាពអស់កល្បជានិច្ច ។

ពួកយើងថ្លែងអំណរគុណសម្រាប់អំណោយទាននៃជីវិត សម្រាប់រូបកាយនិងគំនិតដ៏អស្ចារ្យដែលអនុញ្ញាតឲ្យយើងរីកចម្រើន និងរៀនសូត្រ ។

ពួកយើងអាចអរគុណសម្រាប់សិល្បៈ អក្សរសាស្ត្រ និងតន្ត្រីដែលបីបាច់ព្រលឹងយើង ។

ពួកយើងអាចថ្លែងអំណរគុណសម្រាប់ឱកាសប្រែចិត្ត ចាប់ផ្តើមជាថ្មី កែតម្រូវ និងស្ថាបនាបុគ្គលិកលក្ខណៈ ។

ពួកយើងអាចអរគុណសម្រាប់ក្រុមគ្រួសារ មិត្តភក្តិ និងមនុស្សជាទីស្រឡាញ់ ។

យើងអាចអរគុណសម្រាប់ឱកាសដើម្បីជួយគ្នា ស្រឡាញ់គ្នា និងបម្រើគ្នាទៅវិញទៅមកដែលធ្វើឲ្យជីវិតមានអត្ថន័យកាន់តែខ្លាំង ។

យើងក៏អាចថ្លែងអំណរគុណសម្រាប់ការសាកល្បងដែលយើងបានរៀននូវរឿងទាំងឡាយ ដែលយើងមិនដឹង ។

ភាគច្រើន យើងអាចអរគុណចំពោះព្រះ ជាព្រះវរបិតានៃវិញ្ញាណយើង ដែលធ្វើឲ្យយើងជាបងប្អូនប្រុសស្រីនឹងគ្នា—ជាក្រុមគ្រួសារសាកលដ៏អស្ចារ្យមួយ ។

ជាវេជ្ជបណ្ឌិត ខ្ញុំស្គាល់តម្លៃនៃការព្យាបាលល្អ ។ ដូច្នេះ មិត្តជាទីស្រឡាញ់ ខ្ញុំសូមចេញវេជ្ជបញ្ជាពីរយ៉ាង ដើម្បីជួយយើង*ពិសោធន៍*អំណាចព្យាបាលនៃការដឹងគុណ ។

ដំបូង ខ្ញុំអញ្ជើញបងប្អូន—នៅប្រាំពីរថ្ងៃទៀត—ឲ្យបង្ហេរប្រព័ន្ធផ្សព្វផ្សាយទៅ*ជាទិន្នានុប្បវត្តិដឹងគុណ*ផ្ទាល់ខ្លួនវិញ ។ សូមបង្ហោះ*អ្វី*ដែលបងប្អូនមានអំណរគុណ *នរណា*ដែលបងប្អូនមានអំណរគុណ និង*មូលហេតុ*ដែលបងប្អូនមានអំណរគុណរាល់ថ្ងៃ ។ នៅចុងថ្ងៃទី ៧ ចូរមើលតើបងប្អូនមានអារម្មណ៍កាន់តែរីករាយ និងសុខសាន្តដែរឬទេ ។ ប្រើសញ្ញា# ថ្លែងអំណរគុណ ។ ពេលធ្វើការរួមគ្នា យើងអាចធ្វើឲ្យប្រព័ន្ធផ្សព្វផ្សាយសង្គមពោរពេញទៅដោយការដឹងគុណទៅដល់ទិសទាំងបួននៃផែនដី ។ ផ្នែកនេះ ប្រហែលជាការណ៍នេះនឹងបំពេញការសន្យាដែលព្រះបានប្រទានដល់អយ្យកោអ័ប្រាហាំថាតាមរយៈពូជពង្សរបស់លោក « អស់ទាំងគ្រួសារនៅលើផែនដីនឹងបានពរ » ។[6]

ទីពីរ ចូរយើងរួមគ្នាថ្លែងអំណរគុណចំពោះព្រះតាមការអធិស្ឋានប្រចាំថ្ងៃ ។ ព្រះយេស៊ូវគ្រីស្ទបានបង្រៀនពួកសិស្សទ្រង់ឲ្យអធិស្ឋាន សម្តែងការដឹងគុណចំពោះព្រះជាមុនរួចហើយទូលសូមទ្រង់នូវអ្វីៗដែលយើងត្រូវការ ។ ការអធិស្ឋាននាំមកនូវអព្ភូតហេតុ ។

ក្នុងន័យនោះ ឥឡូវ ខ្ញុំសូមអធិស្ឋានសម្រាប់ពិភពលោក និងមនុស្សគ្រប់រូបនៅលើផែនដីនេះ ។ ពេលខ្ញុំអធិស្ឋាន ខ្ញុំសង្ឃឹមថា បងប្អូននឹងទទួលអារម្មណ៍បំផុសគំនិតឲ្យធ្វើដូចគ្នា គឺ សម្តែងការដឹងគុណចេញពីចិត្តបងប្អូនចំពោះពរជ័យរាប់មិនអស់ដែលព្រះប្រទានឲ្យ ហើយទូលសូមទ្រង់ឲ្យព្យាបាលដួងចិត្តយើងក្រុមគ្រួសារយើង សង្គមជាតិយើង និងពិភពលោកទាំងមូល ។

ព្រះវរបិតាសួគ៌អើយ ក្នុងនាមជាអ្នកដំណើរនៅលើផែនដី ពួកយើងសូមអធិស្ឋានដោយរាបសារទៅ កាន់ទ្រង់ ។ ពួកយើង អរព្រះគុណចំពោះជីវិត និងអ្វីៗដែលទ្រទ្រង់ជីវិត ។ ពួកយើងសូមអរព្រះគុណទ្រង់ចំពោះភាពស្រស់ស្អាតនៃផែនដីនេះ និងរបៀបរៀបរយក្នុងសកលលោក ភពនានា ដួងតារា និងអ្វីៗដែលសំខាន់ដ៏អស់កល្ប ។ ពួកយើងអរព្រះគុណចំពោះក្រឹត្យវិន័យដែលការពារ និងដឹកនាំយើង ។ ពួកយើងអរព្រះគុណចំពោះការមើលថែដោយក្តីមេត្តា និងក្តីស្រឡាញ់ ។ ពួកយើងអរព្រះគុណចំពោះក្រុមគ្រួសារ និងមនុស្សជាទីស្រឡាញ់ដែលបានបំពេញជីវិតយើងដោយអំណរ ។

ពួកយើងមានអំណរគុណចំពោះអ្នកដែលកំពុងពុះពារនឹងជំងឺរាតត្បាតកូវីដនេះ ។ សូមទ្រង់ប្រទានពរដល់ពួកគេនូវការការពារ និងការបំផុសគំនិត ។ សូមទ្រង់ជួយបញ្ចប់វីរុសដែលបានញាំញីដល់កូនចៅទ្រង់ជាច្រើននេះបានឬទេ ?

ពួកយើងអរព្រះគុណចំពោះថ្នាក់ដឹកនាំប្រទេស និងមនុស្សផ្សេងទៀតដែលខិតខំជួយលើកស្ទួយយើង ។ ពួកយើងសូមអធិស្ឋានឲ្យជម្លោះនយោបាយបានរសាយទៅ ។ សូមទ្រង់ប្រទានពរពួកយើងនូវវិញ្ញាណនៃការព្យាបាលមួយដែលរួបរួមយើង ទោះជាមានភាពខុសគ្នាក្តីបានឬទេ ?

សូមទ្រង់ជួយពួកយើងឲ្យប្រែចិត្តពីភាពអាត្មានិយម ភាពអសប្បុរស ភាពឆ្មើងឆ្មៃ និងការរើសអើងគ្រប់រូបភាព ដើម្បីយើងអាចបម្រើ ហើយស្រឡាញ់គ្នាកាន់តែខ្លាំង ក្នុងនាមជាបងប្អូនប្រុសស្រី និងជាកូនចៅដ៏មានអំណរគុណរបស់ទ្រង់ផងបានដែរឬទេ ? ឱ! ព្រះបិតាជាទីស្រឡាញ់ពួកយើងស្រឡាញ់ទ្រង់ និងអធិស្ឋានទូលសូមព្រះពរ ក្នុងនាមនៃព្រះរាជបុត្រាដ៏ស្ងួនភ្ងាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

សូមព្រះប្រទានពរបងប្អូនគ្រប់រូប ។

**កំណត់ចំណាំ**

[១] នៅ មីនណេប៉ូ រដ្ឋមីនីសូតា ខែមីនា ឆ្នាំ១៩៥១។
[២] ទំនុកដំកើង ៩២:១
[៣] ទំនុកដំកើង ១៣៦:១
[៤] ទំនុកដំកើង ៩៥:២
[៥] ថែស្សាឡូនីច ទី១ ៥:១៨
[៦] លោកុប្បត្តិ ១២:៣

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2020 by Intellectual Reserve, Inc. All rights reserved. Version: 10/20. PD60012115 258